ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល (NSW Health)

ការចាក់វ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ACWY

សន្លឹកព័ត៌មានសម្រាប់ឪពុកម្តាយ

រដ្ឋាភិបាលអូស្ត្រាលីផលិតវ៉ាក់សាំងមួយចំនួនដោយឥតគិតថ្លៃនៅក្រោមកម្មវិធីចាក់ថ្នាំបង្ការថ្នាក់ជាតិ (NIP)។

សំណួរ៖ តើអ្វីទៅជំងឺ Meningococcal (មេនិញជោខូកខល)?

ជំងឺ Meningococcal (មេនិញជោខូកខល) គឺកម្រកើតមាន ប៉ុន្តែវាជារោគឆ្លងដ៏ធ្ងន់ធ្ងរមួយ។ ជាធម្មតាវាបណ្តាលឱ្យកើតរោគរលាកស្រោមខួរ (ការរលាកខួរក្បាល និងខួរឆ្អឹងខ្នង) និង/ឬ ការពុលដោយមានបាក់តេរីចូលក្នុងខ្លួន។

រោគសញ្ញានានាអាចរួមមាន៖

- **គ្រុនក្តៅមួយរំពេច**
- **ឈឺក្បាល**
- **រឹងនៅក**
- **ឈឺសន្លាក់**
- **កន្ទួលពណ៌ក្រហម-ពណ៌ស្វាយ ឬស្នាមជាំ**
- **ភាពរសើបចំពោះពន្លឺភ្លឺ**
- **ការចង្អោរ និងការក្អួត**

រហូតដល់ទៅ 10% នៃការឆ្លងរោគ Meningococcal (មេនិញជោខូកខល) បណ្តាលឱ្យស្លាប់ ទោះបីជាការព្យាបាលដោយថ្នាំអង់ទីប៊ីយោទិចសមស្របក៏ដោយ។ អ្នកនៅរស់រានមានជីវិតអាចនឹងបន្សល់ទុកនូវផលវិបាករយៈពេលវែង។

សំណួរ៖ តើជំងឺ Meningococcal (មេនិញជោខូកខល) ឆ្លងរាលដាលយ៉ាងដូចម្តេចដែរ?

បាក់តេរី Meningococcal (មេនិញជោខូកខល) ឆ្លងរវាងមនុស្សតាមទឹកមាត់ពីច្រមុះ និងបំពង់ក។ ជាទូទៅ វាទាមទារឱ្យមានការប៉ះពាល់ជិតស្និទ្ធ និងការប៉ះពាល់យូរជាមួយអ្នកមានបាក់តេរី ដែលជាធម្មតាមានសុខភាពល្អទាំងស្រុង។ ឧទាហរណ៍នៃ 'ការប៉ះពាល់ជិតស្និទ្ធ និងការប៉ះពាល់យូរ' គឺការរស់នៅជាមួយគ្រួសារតែមួយ ឬការថើបយ៉ាងជ្រាលជ្រៅ។ បាក់តេរី Meningococcal (មេនិញជោខូកខល) មិនឆ្លងរាលដាលដោយងាយស្រួលនោះទេ ហើយក៏មិនរស់នៅខាងក្រៅរាងកាយបានយូរដែរ។

សំណួរ៖ តើវ៉ាក់សាំងដំណើរការយ៉ាងដូចម្តេច?

វ៉ាក់សាំងជួយប្រព័ន្ធភាពស៊ាំរបស់អ្នកប្រឆាំងនឹងការឆ្លងមេរោគ។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងប៉ះពាល់នឹងការឆ្លងមេរោគទាំងនេះ ប្រព័ន្ធភាពស៊ាំរបស់ពួកគេអាចទប់ទល់នឹងជំងឺនេះបានប្រសើរជាងមុន ទាំងការទប់ស្កាត់ការវិវត្តនៃជំងឺ ឬធ្វើឱ្យវាមិនសូវធ្ងន់ធ្ងរ។

សំណួរ៖ តើវ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ACWY មានប្រសិទ្ធភាពយ៉ាងណាដែរ?

វ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ACWY មួយដូសមានប្រសិទ្ធភាពខ្លាំងណាស់ប្រឆាំងនឹងជំងឺ Meningococcal (មេនិញជោខូកខល) បួនប្រភេទ (ប្រភេទ A, C, W និង Y)។ វាមិនការពារពីជំងឺប្រភេទ B ទេ។

សំណួរ៖ តើអ្នកណាគួរចាក់វ៉ាក់សាំងនេះ?

សិស្សថ្នាក់ទី 10 ទាំងអស់ដែលរៀននៅអនុវិទ្យាល័យ និង/ឬអ្នកដែលមានអាយុពី 15-19 ឆ្នាំគួរតែចាក់វ៉ាក់សាំងនេះ ដើម្បីការពារប្រឆាំងនឹងជំងឺ Meningococcal (មេនិញជោខូកខល) ប្រភេទ A, C, W, និង Y។

សំណួរ៖ តើអ្នកណាមិនគួរចាក់វ៉ាក់សាំងនេះ?

វ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ACWY មិនគួរត្រូវបានចាក់ឱ្យមនុស្សដែលមាន៖

- **មាន ឬអាចមានផ្ទៃពោះ**
- **ធ្លាប់មានប្រតិកម្មអាណាហ្វីឡាក់ទិច បន្ទាប់ពីដូសនៃវ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ពីមុន**
- **ធ្លាប់មានប្រតិកម្មអាណាហ្វីឡាក់ទិច បន្ទាប់ពីថ្នាំបន្ថែមវ៉ាក់សាំងណាមួយ**
- **បានដឹងពីការសង្ស័យស្រាវជ្រាវខ្លាំងចំពោះប្រតិកម្មទៅនឹងវ៉ាក់សាំងការពារជំងឺតេតាណូស។**

សំណួរ៖ តើអ្វីទៅប្រតិកម្មអាណាហ្វីឡាក់ទិច (anaphylaxis)?

អាណាហ្វីឡាក់ទិច គឺជាប្រតិកម្មអាឡែហ្ស៊ីធ្ងន់ធ្ងរ ដែលអាចបណ្តាលឱ្យសន្លប់ ឬស្លាប់ប្រសិនបើមិនបានព្យាបាលឱ្យបានឆាប់រហ័ស។ វាកម្រណាស់បន្ទាប់ពីចាក់វ៉ាក់សាំងហើយ។ អ្នកផ្តល់សេវាចាក់ថ្នាំបង្ការត្រូវបានបណ្តុះបណ្តាលដើម្បីព្យាបាលប្រតិកម្មអាណាហ្វីឡាក់ទិច (anaphylaxis)។

សំណួរ៖ តើវ៉ាក់សាំងមានសុវត្ថិភាពប៉ុណ្ណាដែរ?

វ៉ាក់សាំងនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាពណាស់។ វ៉ាក់សាំងទាំងនោះត្រូវតែឆ្លងកាត់ការត្រួតពិនិត្យសុវត្ថិភាពយ៉ាងតឹងរ៉ឹង មុនពេលរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA) អនុម័តលើវា។ TGA ក៏តាមដានវ៉ាក់សាំងផងដែរ បន្ទាប់ពីវ៉ាក់សាំងទាំងនោះត្រូវបានប្រើប្រាស់។

សំណួរ៖ តើវ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ACWY មានផ្ទុកអ្វីខ្លះ?

វ៉ាក់សាំងអាចមានផ្ទុក ត្រួតតាម៉ុល ជាតិស្ករក្នុងរុក្ខជាតិ សូដ្យូមក្លរាយ សូដ្យូមអាសេតាត និងទឹក។ គ្រឿងផ្សំទាំងនេះត្រូវបានបន្ថែមក្នុងបរិមាណតិចតួចដើម្បីជួយឱ្យវ៉ាក់សាំងដំណើរការ ឬរក្សាវាបានយូរ។

សំណួរ៖ តើកូនរបស់ខ្ញុំមិនទាន់បានចាក់វ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ACWY ទេឬ? តើវាមានសុវត្ថិភាពក្នុងការចាក់វាម្តងទៀតទេ?

វ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ACWY ត្រូវបានចាក់សម្រាប់កុមារអាយុ 12 ខែ ចាប់តាំងពីខែកក្កដា ឆ្នាំ 2018។ កូនរបស់អ្នកប្រហែលជាធ្លាប់បានចាក់វ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ប្រភេទ C ពីមុនមក។ វ៉ាក់សាំងនោះការពារតែជំងឺ Meningococcal (មេនិញជោខូកខល) ប្រភេទ C ប៉ុណ្ណោះ។

នៅប្រទេសខ្លះ ការចាក់ដូសជំរុញសម្រាប់ក្មេងជំទង់ត្រូវបានណែនាំ។ វ៉ាក់សាំងជំងឺ ACWY នេះផ្តល់ការការពារប្រឆាំងនឹងជំងឺ Meningococcal (មេនិញជោខូកខល) ប្រភេទ C ក៏ដូចជាប្រភេទ A, W, និង Y។

ក្មេងជំទង់មួយចំនួនដែលមានស្ថានភាពសុខភាពជាក់លាក់មួយចំនួន (ដូចជាគ្មានសរីរាង្គអណ្តើកក្នុងខ្លួន ឬការថមថយភាពស៊ាំ) ប្រហែលជាបានចាក់វ៉ាក់សាំងនេះរួចហើយ។ បើដូច្នេះមែន សូមពិគ្រោះជាមួយ GP (វេជ្ជបណ្ឌិតព្យាបាលជំងឺទូទៅ) ឬអ្នកឯកទេសរបស់អ្នក ដើម្បីមើលថាតើកូនរបស់អ្នកត្រូវការចាក់មួយដូសទៀតឬអត់។

សំណួរ៖ តើអ្នកណាផ្សេងទៀតដែលគួរចាក់វ៉ាក់សាំងនេះ?

វ៉ាក់សាំងនេះត្រូវបានណែនាំសម្រាប់៖

- **មនុស្សដែលធ្វើដំណើរទៅកាន់តំបន់មានហានិភ័យខ្ពស់នៃជំងឺ Meningococcal (មេនិញជោខូកខល) ដូចជា Hajj ជាដើម**
- **បុគ្គលិកមួយចំនួន ដូចជាបុគ្គលិកមន្ទីរពិសោធន៍មីក្រូជីវវិទ្យា**
- **មនុស្សដែលមានលក្ខណៈផ្នែកវេជ្ជសាស្ត្រ ដូចជាអ្នកទាំងនោះដែលគ្មានសរីរាង្គអណ្តើកក្នុងខ្លួន។**

សំណួរ៖ តើវ៉ាក់សាំងជំងឺ Meningococcal (មេនិញជោខូកខល) ACWY មានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

ផលប៉ះពាល់បន្ទាប់បន្សំជាធម្មតាគឺស្រាល។ ផលប៉ះពាល់បន្ទាប់បន្សំទាំងនេះអាចរួមមាន៖

- **គ្រុន**
- **ឈឺក្បាល**
- **វិលមុខ**
- **ការឈឺចាប់ ក្រហម ឬការហើមនៅកន្លែងចាក់វ៉ាក់សាំង។**

ផលប៉ះពាល់បន្ទាប់បន្សំទាំងនេះជាធម្មតាបាត់ទៅវិញក្នុងរយៈពេល 2-3 ថ្ងៃ។ ផលប៉ះពាល់បន្ទាប់បន្សំធ្ងន់ធ្ងរគឺកម្រមានណាស់។

សម្រាប់ព័ត៌មានលម្អិតអំពីផលប៉ះពាល់បន្ទាប់បន្សំ សូមចូលមើលនៅតាមគេហទំព័រ health.nsw.gov.au/schoolvaccination និងពិនិត្យមើលព័ត៌មានអំពីឱសថសម្រាប់អ្នកប្រើប្រាស់ (CMI)។

ប្រសិនបើអ្នកព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំ សូមទាក់ទង GP (វេជ្ជបណ្ឌិតព្យាបាលជំងឺទូទៅ) របស់អ្នក។ ពួកគេក៏អាចរាយការណ៍ពីកង្វល់ណាមួយទៅកាន់អង្គភាពសុខភាពសាធារណៈក្នុងតំបន់ផងដែរ។

សំណួរ៖ តើខ្ញុំអាចទទួលបានកំណត់ត្រាការចាក់វ៉ាក់សាំងរបស់កូនខ្ញុំដោយរបៀបណា?

ព័ត៌មានលម្អិតអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នកនឹងត្រូវបានបញ្ចូលទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។

ឪពុកម្តាយអាចទទួលបានច្បាប់ចម្លងនៃសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរបស់កូនពួកគេរហូតដល់កូនដល់អាយុ 14 ឆ្នាំ។ សិស្សដែលមានអាយុចាប់ពី 14 ឆ្នាំ និងអាយុលើសនេះអាចទទួលបានកំណត់ត្រាផ្ទាល់ខ្លួនរបស់ពួកគេ។ អ្នកអាចចូលប្រើវា៖

- **តាមរយៈគណនីអនឡាញ Medicare របស់អ្នកនៅតាមគេហទំព័រ my.gov.au**
- **ដោយប្រើកម្មវិធី Medicare Express Plus App នៅតាមគេហទំព័រ servicesaustralia.gov.au/express-plus-mobile-apps**
- **ដោយការហៅទូរសព្ទទៅបណ្តាញទូរសព្ទស៊ើបសួរទូទៅ AIR (AIR General Enquiries Line) តាមលេខ 1800 653 809។**